# បទឧទ្ទេសនាម ស្តីពី ការផ្តល់សេវាកម្មទឹកស្អាតប្រកបដោយនិរន្តរភាព
# នៃការផ្គត់ផ្គង់ទឹកស្អាត សាធារណៈ និងឯកជន



ក្រោមកម្មវិធីអនាម័យ និងទឹកស្អាត (WSP) របស់ធនាគារពិភពលោក (WB) បទឧទ្ទេសនាម ស្តីពីការផ្តល់សេវាកម្មទឹកស្អាត ប្រកបដោយនិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាត សាធារណៈ និងឯកជន ដែលជាជំនួយឧបត្ថម្ភរបស់ធនាគារពិភពលោក សហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបានរៀបចំធ្វើឡើង នៅព្រឹកថ្ងៃទី១៥ ខែ មករា ឆ្នាំ២០១៥ នៅសាលប្រជុំរដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។



លោក **Alassane Sow** ប្រធានធនាគារពិភពលោកប្រចាំកម្ពុជា បានបង្ហាញពីការយកចិត្តទុកដាក់និងសកម្មភាពការងាររបស់ធនាគារពិភពលោក ក្នុងការចូលរួមគម្រោងអភិវឌ្ឍន៍ផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា ជាពិសេសគម្រោងទឹកស្អាតជនបទ និងសម្រាប់ជនក្រីក្រ ក្នុងគោលដៅលើកកំពស់សុខភាពអនាម័យ និងការកាត់បន្ថយភាពក្រីក្រ ។ លោកបានបញ្ជាក់ថា: គោលបំណងនៃកម្មវិធីបទឧទ្ទេសនាមនេះ គឺ: –បង្កើនការយល់ដឹងអំពីបញ្ហាប្រឈម និងកាលានុវត្តភាពសម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកឯកជន–សេចក្តីសង្ខេប ស្តីពីជំនួយបច្ចេកទេសរបស់ WSP –ការចែករំលែកមេរៀនជាសកល ស្តីពីការលើកកំពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន និងការផ្តល់សេវាគាំទ្រដល់ជនក្រីក្រ–ពិគ្រោះយោបល់លើការលើកកំពស់ការអនុវត្ត និងការគាំទ្ររបស់WSP ក្នុងពេលអនាគត ។

មានប្រសាសន៍បើកកិច្ចប្រជុំ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានថ្លែអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះធនាគារពិភពលោក ដែលបានធ្វើសកម្មភាពយ៉ាងសកម្មភាព លើវិស័យទឹកស្អាតនៅកម្ពុជា ។ បទឧទ្ទេសនាមថ្ងៃនេះពិតជាមានសារៈសំខាន់ណាស់ សម្រាប់ជាបទពិសោធន៍ និងការយល់ដឹងបន្ថែម ដល់ប្រតិបត្តិករទឹកស្អាតទាំងវិស័យសាធារណៈ និងឯកជន ។ ពីព្រោះវិស័យទឹកស្អាត ជាវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល ជាពិសេស គឺមានការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់បំផុតពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ** ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលចង់ឱ្យប្រជាពលរដ្ឋទូទៅទទួលបាន សេវាទឹកស្អាតគ្រប់ៗគ្នា ពីព្រោះការពិសារទឹកស្អាត មានន័យថា: ប្រជាពលរដ្ឋកំពុងទទួលបាននូវសេវាសុខភាពដ៏ប្រសើរ ដែលធ្វើឱ្យគ្រួសារមានសុភមង្គល ។ ជាមួយគ្នានេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរាជរដ្ឋាភិបាល អណត្តិទី៥នេះ បានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះវិស័យផ្គត់ផ្គង់ទឹកស្អាត ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សន៍ ។ ក្នុងនោះ ទីតាំងកន្លែងណាដែលរដ្ឋមិនទាន់មានលទ្ធភាពវិនិយោគ គឺយើងបានផ្តល់សិទ្ធិឱ្យផ្នែកឯកជនវិនិយោគ តែត្រូវអនុវត្តឱ្យស្របតាមប្រកាសលេខ ៤៦១ MIH/2014 ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្តីពីនីតិវិធីនៃការចេញ កែសម្រួល បន្ត ឭ និងដកហូតប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ។ ទោះជាយ៉ាងណា តាមរយៈបទឧទ្ទេសនាមនេះ យើងនឹងទទួលបាននូវការចែករំលែកបទពិសោធន៍ល្អៗ សម្រាប់យើងធ្វើការពិចារណា និងសម្របសម្រួលធ្វើយ៉ាងណា ឱ្យអ្នកផ្តល់សេវាទឹកស្អាត ជាពិសេសផ្នែកឯកជន មានលទ្ធភាពគ្រប់គ្រាន់ ទាំងទុនវិនិយោគ ការពង្រីកបណ្តាញ និងមានច្បាប់ទម្លាប់ត្រឹមត្រូវ ពីព្រោះការផ្គត់ផ្គង់ទឹកស្អាតយើងត្រូវគិតទៅលើកត្តាយ៉ាងតិច០៤យ៉ាង គឺគុណភាព–សុវត្ថិភាព–និរន្តរភាព និងតម្លៃសមរម្យ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានអំពាវនាវ ដល់អ្នកផ្គត់ផ្គង់ទឹកស្អាតឯកជន ដែលមិនទាន់មានច្បាប់អនុញ្ញាត រឺធ្វើអាជីវកម្ម មុនប្រកាសលេខ ៤៦១ MIH/2014 ត្រូវមកសុំច្បាប់អនុញ្ញាត ដើម្បីទទួលសិទ្ធិស្របច្បាប់ ធ្វើអាជីវកម្ម ។ ទទួលបានសិទ្ធិស្របច្បាប់ហើយ ឯកឧត្តម បានស្នើឱ្យក្រុមហ៊ុនពិនិត្យលទ្ធភាព ចងក្រងជាសមាគមទឹកស្អាត ដើម្បីទទួលបានអត្ថប្រយោជន៍ផ្សេងៗ ពីសមាគម ក៏ដូចជា គោលនយោបាយនានារបស់រដ្ឋ និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត។

ជាចុងក្រោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្នើឱ្យរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពិនិត្យលទ្ធភាពនាំចូល ម៉ាស៊ីនផ្គត់ផ្គង់ទឹកស្អាតអេឡិចត្រូនិក ដែលប្រទេសមួយចំនួនលើពិភពលោកធ្លាប់ និងកំពុងប្រើប្រាស់ ដែលហៅថា: **(Pre-Paid Meters)** ដែលម៉ាស៊ីននេះ អតិថិជនអាចទិញកាតមកប្រើប្រាស់ តាមរយៈការស៊ិកកាតនោះក្នុងម៉ាស៊ីន និងចុច

បញ្ហាជាវទឹកតាមតម្រូវការ អាស្រ័យលើតម្លៃទឹកប្រាក់ ដែលមានក្នុងកាត ។ ការធ្វើបែបនេះ គឺដើម្បីសម្រួលដល់ប្រជាពលរដ្ឋក្នុងតំបន់ណាមួយ ដូចជាតំបន់ឆ្ងាយពីទីប្រជុំជន តំបន់ដាច់ស្រយាល រឺតំបន់មានដង់ស៊ីតេប្រជាជនតិច ដើម្បីឱ្យពួកគាត់មានលទ្ធភាពទទួលបានប្រព័ន្ធទឹកស្អាតដូចគេឯង ប្រកបដោយអនាម័យ និងមានតម្លៃដូចគ្នា ។ ពីព្រោះការតបណ្តាញដល់ផ្ទះពួកគាត់ត្រូវចំណាយថវិកាច្រើន ។

បន្ទាប់មកអង្គពិធី បានតាមដានស្តាប់បទបង្ហាញជាបន្តបន្ទាប់ ពីវាគ្មិនអ្នកជំនាញខាងទឹកស្អាត និងអនាម័យនៃធនាគារពិភពលោក នូវប្រធានបទមួយចំនួន ដូចជាៈកាលានុវត្តភាព និងបញ្ហាប្រឈម ចំពោះការផ្គត់ផ្គង់ទឹកស្អាត ដោយវិស័យឯកជន ខ្លឹមសារលំអិត របស់កម្មវិធីជំនួយបច្ចេកទេស–បទបង្ហាញអំពីស្ថានភាពរបស់វិស័យទឹកស្អាត និងភស្តុតាងបញ្ជាក់ពីកាលានុវត្តភាព និងបញ្ហាប្រឈមរបស់វិស័យឯកជន–បទបង្ហាញអំពីកម្មវិធីជំនួយបច្ចេកទេសរបស់កម្មវិធីទឹកស្អាត និងអនាម័យ បទពិសោធន៍ដែលទទួលបានកន្លងមក និងអនុសាសន៍សម្រាប់ការអនុវត្តគម្រោង រហូតដល់ខែកញ្ញា ឆ្នាំ២០១៥–ការចែករំលែកបទពិសោធន៍របស់ប្រទេសផ្សេងៗ អំពីភាពជាដៃគូរវាងវិស័យសាធារណៈជាមួយឯកជន (PPP) និងគោលនយោបាយនៃការផ្តល់សេវាដោយឥតដល់ប្រជាជន–ការពិភាក្សាអំពីមាគ៌ាអភិវឌ្ឍន៍ប្រទេសកម្ពុជា និងការ គាំទ្រនៅថ្ងៃអនាគតរបស់កម្មវិធីរបស់កម្មវិធីទឹកស្អាត និងអនាម័យ–បទពិសោធន៍របស់ប្រទេសលើពិភពលោក អំពីភាពជាដៃគូរវាងវិស័យសាធារណៈជាមួយឯកជន (PPP) និងការប្រើប្រាស់ឧបត្ថម្ភធន រឺជំនួយដល់ប្រជាជនក្រីក្រ ។

បន្ទាប់មកអង្គពិធីបានអនុញ្ញាតឱ្យមានការលើកសំណួរ ចំលើយ ទាក់ទងនិងកិច្ចពិភាក្សាអំពីការបន្តអនុវត្តជំនួយបច្ចេកទេស និងអំពីមាគ៌ាអភិវឌ្ឍន៍ប្រទេសកម្ពុជា និងការគាំទ្រទៅថ្ងៃអនាគតរបស់កម្មវិធីទឹកស្អាត និងអនាម័យ (WSP) ។

មានប្រសាសន៍បិទកម្មវិធី ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះសិក្ខាសាលារយៈពេលពេញមួយព្រឹកនេះ និងថ្លែអំណរគុណដល់ ធនាគារពិភពលោក (WB) និងអង្គការ JICA ជប៉ុន ជាដៃគូសហការឧបត្ថម្ភដ៏សំខាន់លើវិស័យទឹកស្អាតនៅកម្ពុជា ។ ចំពោះការពិភាក្សាអំពីរបៀបសម្រាប់តើការវិស័យឯកជន ដែលត្រៀមរៀបចំនាពេលខាងមុខ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានកំណត់យកខែ មីនា ឆ្នាំ២០១៥ ក្រោមប្រធានបទ ៖ភាពជាដៃគូរវាងវិស័យសាធារណៈជាមួយឯកជន (PPP) ។



